- ហាមដាច់ខាតដកប្រាក់ចំណូល «ផ្សេងៗ» ដើម្បីបំពេញមុខចំណាយហួសក្រៅក្របខ័ណ្ឌដែលត្រូវកំណត់ដោយច្បាប់ ។

ផែនការគោលការណ៍ទូទៅ ឬ រាល់កិច្ចប្រតិបត្តិការចំណាយប្រចាំឆ្នាំត្រូវគិតគូរប្រតិបត្តិអោយបានសំរេចតាមកម្មវិធីគ្រោងទុក ។

ប៉ុន្តែបើកិច្ចការ និងគម្រោងចំណាយនេះពុំបានសំរេច ឬ បានមិនគ្រប់តាមកម្មវិធីកំណត់ ដែលអោយបាត់តុល្យភាពថវិកា នោះការប្រើប្រាស់ឥណទាន (ចំណាយ) របស់បណ្តាក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល និងសាលាខេត្តក្រុង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាំបាច់អនុវត្តវិធានការខ្ទង់ចំណាយដូចមានចែងក្នុង មាត្រា៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ។

វិធានការនេះ ពិតជានឹងអាចពង្រឹងនូវវិន័យថវិកា ព្រមទាំងផ្តល់នូវតម្លាភាពច្បាស់លាស់សំរាប់កំណត់ផ្លូវ និងមធ្យោបាយប្រមែប្រមូលប្រភពធនធានក្នុងប្រទេសបង់ជូនរដ្ឋកាន់តែមានប្រសិទ្ធភាព ។

បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នរដ្ឋបាលកណ្តាល ឬ គ្រប់ខេត្ត ក្រុង ក្រោយពីបានទទួលសារាចរនេះ បើមានការជួបការលំបាកដោយប្រការណាមួយជាថាហេតុ ត្រូវរួតរះពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរិះរកវិធីដោះស្រាយនិងណែនាំអនុវត្តអោយបានល្អព្រមទាំងឆ្លើយបញ្ជាក់ពីការទទួល បានសារាចរនេះ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
**គាត ឈន់**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ១៨៥ នបប្រក.សហវ

## ស្តីពីការផ្ទេរភារកិច្ចថ្នាក់ការគយ_រដ្ឋាករ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ន.ស ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញសារាចរស្តីពីការគ្រប់គ្រងមន្ត្រីរាជការគយ និងរដ្ឋាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០១ សហ.សហវ.គរ ចុះថ្ងៃទី០៦ ខែ មករា ឆ្នាំ ១៩៩៥ ។
- បានឃើញលិខិតស្នើសុំរបស់ទីចាត់គយ-រដ្ឋាករលេខ ៥៩៨/៩៦ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦ ។

## សំរេច

**ប្រការ ១** : ត្រូវបានធ្វើការផ្ទេរភារកិច្ចគយរដ្ឋាករ ចំនួន ២៥ នាក់ដូចខាងក្រោម ÷

១-លោក **ហ៊ុយ ស៊ីណេត** បច្ចុប្បន្នបុគ្គលិកសាខាគយនិងរដ្ឋាករ ខេត្តស្ទឹងត្រែង ផ្ទេរភារកិច្ច ទៅជាបុគ្គលិកការិយាល័យគយ និងរដ្ឋាករផែស្ងួត ។

២–លោក ទ្រឹម ចំរើន បច្ចុប្បន្នជា ភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ ពុំក្រមុំ (ខេត្តស្ទឹងត្រែង) ផ្ទេរភារកិច្ចទៅជា បុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្កូត ។

៣–លោក គុជ សុធា បច្ចុប្បន្នជា ភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ អូស្វាយខេត្ត (ស្ទឹងត្រែង) ផ្ទេរភារកិច្ចទៅជា បុគ្គលិកការិយាល័យនិងរដ្ឋាករផៃស្កូត ។

៤–លោក ខេមរ សុផល បច្ចុប្បន្នជា ភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ អូយ៉ាដាវ(ខេត្ត រតនៈគិរី) ផ្ទេរភារកិច្ចទៅជា បុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្កូត ។

៥–លោក ឆេត រាជ បច្ចុប្បន្នជា ភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ អូរាំង ដាក់ដាំ (ខេត្តមណ្ឌលគិរី) ផ្ទេរភារកិច្ច ជាបុគ្គលិកការិយាល័យគយ និងរដ្ឋាករផៃស្កូត

៦–លោក កែវ ស៊ីន បច្ចុប្បន្នភ្នាក់ងារស្នាក់ការគយ និងរដ្ឋាករ ដា (ខេត្តកំពង់ចាម) ផ្ទេរភារកិច្ចទៅជាបុគ្គលិក ការិយល័យគយនិងរដ្ឋាករផៃស្កូត ។

៧–លោក សាំង ណាន បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ មេមត់(ខេត្តកំពង់ចាម)ផ្ទេរភារកិច្ចជាបុគ្គលិក ការិយាល័យគយនិងរដ្ឋាករផៃស្កូត ។

៨–លោក គន់ ស៊ីដារ៉ា បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ ជ័យឃ្លាំង(ខេត្តក្រចេះ)ផ្ទេរភារកិច្ចទៅជា បុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្កូត ។

៩–លោក គីម ឫទ្ធី បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករវ៉ាលិ (ខេត្តក្រចេះ)ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយា ល័យគយនិងរដ្ឋាករផៃស្កូត ។

១០–លោក **ណុប គីមសាន** បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករផ្លូវកែងស្នួល(ខេត្ត ក្រចេះ) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យនិងរដ្ឋាករផៃស្នូត ។

១១–លោក **លួន សំឡេង** បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករបឹងត្រកួន (ខេត្តបន្ទាយមានជ័យ)ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្នូត

១២–លោក **ខិម ឧត្តម** បច្ចុប្បន្នជាភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករអូស្មាច់(ខេត្តបន្ទាយមានជ័យ)ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងដ្ឋាករផៃស្នូត ។

១៣–លោក **សោម សុមនា** បច្ចុប្បន្នជាភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករថ្មស (ខេត្តកោះកុង) ផ្ទេរភារកិច្ចទៅជាបុគ្គលិកិរិយាល័យគយនិង រដ្ឋាករផៃស្នូត ។

១៤–លោក **អន ស៊ីនួន** បច្ចុប្បន្នជាភាក់ងារ ស្នាក់ការគយនិងរដ្ឋាករត្រពាំងល្មៅ(ខេត្ត កំពត) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យនិងរដ្ឋាករផៃស្នូត ។

១៥–លោក **ហុក លីសេង** បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករភ្នំប្ញស្សី (ខេត្តពោធិសាត់)ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងររដ្ឋាករផៃស្នូត ។

១៦–លោក **ច្រឹក ចំនួណា** បច្ចុប្បន្នជាបុគ្គលិកការិយាល័យបុគ្គលិក ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្នូត ។

១៧–លោក **ស្រេង សំណាង** បច្ចុប្បន្ន បុគ្គលិក ការិយាល័យ វិវាទនិងច្បាប់ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្នូត ។

១៨–លោក **សុខ យឿន** បច្ចុប្បន្នជាបុគ្គលិក ការិយាល័យ គណនេយ្យ ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

១៩–លោក **ឡុច សុផល** បច្ចុប្បន្ន បុគ្គលិកការិយាល័យបុគ្គលិកផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

២០–លោក **នួន សុផល** បច្ចុប្បន្នភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករទ្រីវមខេត្តកំពត(ខេត្តកំពត) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

២១–លោក **ជាំ តូក** បច្ចុប្បន្ន ភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករទាន់ហាន់(ខេត្តកំពត)ផ្ទេរភារ កិច្ចជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

២២–លោក **ម៉ក់ សាម៉ុឌី** បច្ចុប្បន្ន ភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករលកព្រែកចាក(ខេត្តកំពត) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

២៣–លោក **ជួប ចំរើន** បច្ចុប្បន្នភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករអូរយ៉ាដាវ(ខេត្តរតនៈគីរី) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

២៤–លោក **ហ៊ាំង លាង** បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយ និង រដ្ឋាករអូរយ៉ាដាវ (ខេត្តរតនគីរី) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

២៥–លោក **ទូ វណ្ណា** បច្ចុប្បន្នភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករប៉ោយប៉ែត(ខេត្តបន្ទាយមានជ័យ)ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករ

ផែស្តួត។

**ប្រការ ២** : សាមីខ្លួនត្រូវមានវត្តមានតាមទីកន្លែងបំពេញភារកិច្ចក្នុងប្រការ ១ យ៉ាងយូរ ១៥ ថ្ងៃ ក្រោយ ទទួលលិខិតបង្គាប់ការ បើហួសការកំណត់នេះ ត្រូវបានចាត់ទុកថា បោះបង់ចោលការងារ ។

**ប្រការ ៣** : លោកអគ្គនាយក នាយកខុទ្ទកាល័យ លោកប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិកទីចាត់ការគយ-រដ្ឋាករនិងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃ ចុះហត្ថលេខាលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

## ២ - នីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៩៨ ឧក.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ ក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល